ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
លេខ...១៩៧/២៥...គជ.

# គោរពជូន

**ឯកឧត្តម ឧត្តមសេនីយ៍ឯក ផាត សុផានិត អគ្គលេខាធិការ**

**នៃអគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ**

**<u>កម្មវត្ថុ</u>៖** សំណើសុំអ្នកកាន់កម្មវិធី (MC) ០១រូប ដើម្បីសម្របសម្រួលក្នុងកម្មវិធី **"ទិវាជាតិអន្តរសាសនាដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស លើកទី៩ ឆ្នាំ២០២៥"** ។

**<u>យោង</u>៖** ចំណារដ៏ខ្ពង់ខ្ពស់បំផុតចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៥ របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ** មេត្តាជ្រាបថា៖ ជារៀងរាល់ឆ្នាំ គិតចាប់ពីឆ្នាំ២០១៧មក គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) តែងតែបានសហការជាមួយសាសនាធំៗ ក្នុងព្រះរាជាណាចក្រកម្ពុជា រៀបចំទិវាជាតិអន្តរសាសនាប្រឆាំងការជួញដូរមនុស្ស ដើម្បីបួងសួងឱ្យប្រជាជនកម្ពុជា ក៏ដូចជាប្រជាជននៅលើពិភពលោក ទទួលបានសេចក្តីសុខ ចៀសផុតពីការរំលោភបំពាន និងអំពើជួញដូរមនុស្ស ដែលជាទាសភាពសម័យទំនើប។ ឆ្នាំ២០២៥នេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) នឹងបន្តរៀបចំទិវាជាតិដ៏មានសារសំខាន់នេះ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** ជាតំណាងដ៏ខ្ពង់ខ្ពស់បំផុត**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលនឹងមានសមាជិករាជរដ្ឋាភិបាល មេដឹកនាំសាសនា មន្ត្រីរាជការ ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ សិស្សនិស្សិត ស្ថានតំណាងបរទេសប្រចាំកម្ពុជា អង្គការដៃគូជាតិ-អន្តរជាតិ និងសាធារណជន ចូលរួមប្រមាណ ១,៥០០ អង្គ/នាក់។

<u>កម្មវិធី</u>៖ ថ្ងៃពុធ ១១រោច ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២០ ខែសីហា ឆ្នាំ២០២៥

<u>ទីកន្លែង</u>៖ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍អន្តរជាតិជ្រោយចង្វារ
(សូមគោរពជូនភ្ជាប់ជាមួយនូវ៖ កម្មវិធី ០១ច្បាប់)

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម ឧត្តមសេនីយ៍ឯក** មេត្តាផ្តល់អ្នកកាន់កម្មវិធី (MC)តាមកាលបរិច្ឆេទខាងលើតាមការគួរ។

សូម **ឯកឧត្តម** មេត្តាទទួលនូវការគោរពរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ៕

*ថ្ងៃ...ពុធ ៦រោច...ខែ...អាសាឍ...ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩*

*រាជធានីភ្នំពេញ, ថ្ងៃទី...១៦...ខែ...កក្កដា...ឆ្នាំ២០២៥*

**អគ្គលេខាធិការ**

ឧត្តមសេនីយ៍ឯកវេជ្ជ.ប៊ុណ្ណ សំខាន់

*-សូមទំនាក់ទំនងតាមរយៈទូរស័ព្ទ*
*ឧ.ទោ វ៉ន សិរីលក្ខិណា -០១៥ ៦៣ ៦៤ ០៧*
*លោក ហាង ជីវ័ន្ត-០៧៧ ៧០១ ២៣៨*